SUN BUCKS

# សិក្សាស្វែងយល់ពីរបៀបដែលកម្មវិធី SUN Bucks អាចជួយផ្តត់ផ្គង់អាហារដល់កុមារ នៅរដូវក្តៅ!



**កម្មវិធី SUN Bucks** គឺជាកម្មវិធីអត្ថប្រយោជន៍គ្រឿងទេស ដើម្បីជួយគ្រួសារទិញអាហារនៅរដូវក្តៅ ពេលសាលារៀនបិទទ្វារ។ កុមារដល់អាយុចូលសិក្សាដែលមានសិទ្ធិទទួលបានម្នាក់ៗនឹងទទួលបានការបង់ប្រាក់តែម្តងគត់ចំនួន **$120**។ កុមារដែលទទួលបានអត្ថប្រយោជន៍ទាំងអស់នេះក៏អាចចូលរួមនៅក្នុងកម្មវិធីអាហាររដូវក្តៅផ្សេងទៀតបានដែរ។

## តើកម្មវិធី SUN Bucks ដំណើរការយ៉ាងដូចម្តេចដែរ?

អត្ថប្រយោជន៍កម្មវិធី SUN Bucks ត្រូវបានបញ្ចូលទៅក្នុង**កាត EBT** ហើយអាចត្រូវបានប្រើប្រាស់ដើម្បីទិញអាហារដូចជា ផ្លែឈើ បន្លែ សាច់ គ្រាប់ធញ្ញជាតិ និងទឹកដោះគោ នៅហាងលក់គ្រឿងទេស ផ្សារកសិករ និងកន្លែងផ្សេងទៀតដែលទទួលយកអត្ថប្រយោជន៍ EBT។

## តើខ្ញុំអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធី SUN Bucks ដោយរបៀបណា?

### ការចុះឈ្មោះដោយស្វ័យប្រវត្តិ

កូនរបស់អ្នកនឹងត្រូវបាន**ចុះឈ្មោះដោយស្វ័យប្រវត្តិ**សម្រាប់ កម្មវិធី SUN Bucks ហើយមិនចាំបាច់ដាក់ពាក្យស្នើសុំទេ ប្រសិនបើ៖

- ពួកគេបានបំពេញពាក្យស្នើសុំអត្ថប្រយោជន៍អាហារសាលា ហើយពួកគេត្រូវបានរកឃើញថាពួកគេមានសិទ្ធិទទួលបាន ឬ
- កុមារដែលមានអាយុពី 6-16 ឆ្នាំដែលជាផ្នែកមួយនៃគ្រួសារដែលបានចុះឈ្មោះនៅក្នុងកម្មវិធី SNAP កម្មវិធី FDPIR កម្មវិធី TANF កម្មវិធី MaineCare រួចហើយ ស្ថិតនៅ 185% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ (FPL) ឬត្រូវបានកំណត់អត្តសញ្ញាណថាជាកុមារដែលគេចិញ្ចឹមថែទាំ គ្មានផ្ទះសម្បែង ឬចំណាកស្រុក ដោយការិយាល័យ OFI ឬ OCFS។

**សូមបន្តតាមដាន!** គ្រួសារដែលបានចុះឈ្មោះដោយស្វ័យប្រវត្តិនឹងចាប់ផ្តើមទទួលបានអត្ថប្រយោជន៍ចាប់ពីខែមិថុនា នៅក្នុងកាត Pine Tree ដែលមានស្រាប់របស់ពួកគេ ឬនៅក្នុងកាត EBT ដែលទើបចេញឱ្យថ្មីតាមប្រៃសណីយ៍។

### ការដាក់ពាក្យស្នើសុំដោយដៃ

**គ្រួសារភាគច្រើននឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិ។ ប្រសិនបើអ្នកមិនបានទទួលលិខិតតាមប្រៃសណីយ៍នៅត្រឹមខែមិថុនាទេ សូមពិចារណាដាក់ពាក្យស្នើសុំកម្មវិធី SUN Bucks មុនថ្ងៃទី 15 ខែសីហា ប្រសិនបើ៖**

- កូនរបស់អ្នកចូលរៀននៅសាលាដែលផ្តល់កម្មវិធីអាហារថ្ងៃត្រង់សាលាជាតិ ឬកម្មវិធីអាហារពេលព្រឹកនៅសាលា និង
- គ្រួសាររបស់អ្នកបំពេញតាមលក្ខខណ្ឌសម្រាប់អត្ថប្រយោជន៍អាហារសាលាដោយឥតគិតថ្លៃ ឬអាហារបញ្ចុះតម្លៃ។

**តើអ្នកបានផ្លាស់ប្តូរអាសយដ្ឋានថ្មីមែនទេ?**

សូមប្រាកដថាអ្នកបានធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នកជាមួយសាលារៀនរបស់អ្នក និងជាមួយការិយាល័យឯករាជ្យភាពគ្រួសារ ដើម្បីឱ្យអត្ថប្រយោជន៍កម្មវិធី **SUN Bucks** របស់អ្នកត្រូវបានផ្ញើទៅកាន់កន្លែងដែលត្រឹមត្រូវ!

សូមធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកដោយហៅទូរសព្ទទៅការិយាល័យ OFI តាមរយៈលេខ (855) 797-4357



**សូមកុំពន្យាពេលក្នុងការប្រើប្រាស់អត្ថប្រយោជន៍របស់អ្នក!**

កម្មវិធី SUN Bucks នឹងផុតសុពលភាពប្រើប្រាស់នៅក្នុងរយៈពេល 122 ថ្ងៃ។

**សម្រាប់ព័ត៌មានបន្ថែមអ្នកអាចស្វែងរកបាននៅ៖** Maine.gov/dhhs/ofi

**ដើម្បីដាក់ពាក្យស្នើសុំ៖** សូមចូលទៅកាន់ MyMaineConnection.gov ឬបំពេញពាក្យស្នើសុំដោយដៃផ្ទាល់តាមក្រដាសនៅ Maine.gov

**មានសំណួរមែនទេ?** សូមហៅទូរសព្ទទៅការិយាល័យ OFI តាមលេខ (855) 797-4357

Maine.gov/dhhs/ofi

Department of Health and Human Services